ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ

ក្រសួងប្រៃសណីយ៍ និងទូរគមនាគមន៍
លេខ ១៣៤ បទ

**គោរពជូន**
**ឯកឧត្តម អៀង ម៉ូលី ទេសរដ្ឋមន្ត្រី**
**និងជាប្រធានអាជ្ញាធរជាតិប្រយុទ្ធនឹងជំងឺអេដស៍**

កម្មវត្ថុ: របាយការណ៍បូកសរុបលទ្ធផលការងារ ប្រចាំឆ្នាំ២០១៤ និង លើកទិសដៅ ឆ្នាំ២០១៥ របស់គណៈកម្មាធិការប្រយុទ្ធនឹងជំងឺអេដស៍ក្រសួងប្រៃសណីយ៍ និងទូរគមនាគមន៍ ។

យោង: លិខិតលេខ១៥១១ បទ.ផកហវ.ចុះថ្ងៃទី២៩ ខែ ធ្នូ ឆ្នាំ២០១៤។

តបតាមកម្មវត្ថុ និងយោងខាងលើ ខ្ញុំសូមជម្រាបជូន **ឯកឧត្តមទេសរដ្ឋមន្ត្រី** មេត្តាជ្រាប អំពីលទ្ធ-ផលការងារ ឆ្នាំ២០១៤ និងលើកទិសដៅកាងារឆ្នាំ២០១៥ របស់គណៈកម្មាធិការប្រយុទ្ធ នឹងជំងឺអេដស៍ក្រសួងប្រៃសណីយ៍ និង ទូរគមនាគមន៍ (គ.ប.ជ.អ.ប.ទ)ដែលមានខ្លឹមសារដូចខាងក្រោម:

**I-លទ្ធផលការងារ ឆ្នាំ២០១៤**

**ក-សកម្មភាពជាមួយ អ.ជ.ប.ជ.អ.**

១-ក្រុមប្រឹក្សាគោលនយោបាយ:

-បានចូលរួមប្រជុំក្រុមការងារបច្ចេកទេស រវាងរាជរដ្ឋាភិបាល និងដៃគូរអភិវឌ្ឍន៍ស្តីពីមេរោគអេដស៍ និងជំងឺអេដស៍ នៅទីស្តីការ អ.ជ.ប.ជ.អ.បាន ១លើក ។

-បានជួយអន្តរាគមន៍ សម្របសម្រួល ជាមួយ TRC ក្នុងការស្នើទៅប្រតិបត្តិករទូរស័ព្ទចល័តឲ្យផ្ញើសារខ្លីអប់រំអំពីបញ្ហាអេដស៍ បញ្ជូនទៅកាន់ទូរស័ព្ទដៃ តាមសំណើរបស់អាជ្ញាធរជាតិប្រយុទ្ធនឹងជំងឺអេដស៍ ក្នុងឱកាសបុណ្យអុំទូក បណ្តែតប្រទីប អកអំបុក សំពះព្រះខែ ថ្ងៃទី៥-៧ ខែវិច្ឆិកា ឆ្នាំ២០១៤ និងបន្តផ្សព្វផ្សាយនៅថ្ងៃទី១ ខែធ្នូ ឆ្នាំ២០១៤ នាឱកាសទិវាពិភពលោកប្រយុទ្ធនឹងជំងឺអេដស៍ ។

ទន្ទឹមនឹងសារអប់រំអំពីអេដស៍ តាមទូរស័ព្ទដៃ ក៏បានជួយអន្តរាគមសម្របសម្រួលផ្សព្វផ្សាយសារអប់រំអំពីបញ្ហាគ្រឿងញៀនតាមសំណើអាជ្ញាធរជាតិប្រយុទ្ធប្រឆាំងគ្រឿងញៀន នាឱកាសបុណ្យអុំទូកដូចគ្នា។

-បានចូលរួមប្រជុំជាមួយអ.ជ.ប.ជ.អ.តាមការអញ្ជើញ ដើម្បីស្តាប់របាយការណ៍អំពីសកម្មភាពរយៈពេល៦ខែ របស់អង្គការ One World បន្ទាប់ពីបានទទួលលេខទូរស័ព្ទខ្លី ១២៩៣ ពី TRC និងក្រសួងបទ.ដោយបានផ្តល់អនុសាសន៍គន្លឹះដល់អង្គការនេះ អំពីមធ្យោបាយមានប្រសិទ្ធិភាព ធ្វើឲ្យសាធារណជនងាយស្គាល់ និងនិយមប្រើប្រាស់លេខ ១២៩៣ ក្នុងការសរសេរសារសួរ/ទទួលចម្លើយតាមទូរស័ព្ទដៃដោយឥតគិតថ្លៃ អំពីបញ្ហាអេដស៍ សុខភាពបន្តពូជ សុខភាពផ្លូវភេទ នៅទីស្តីការអាជ្ញាធរជាតិប្រយុទ្ធនឹងជំងឺអេដស៍នាថ្ងៃទី២១ ខែវិច្ឆិកា ឆ្នាំ ២០១៤។

-បានបញ្ជូនមន្ត្រី២រូប ចូលរួមវគ្គបណ្តុះបណ្តាលស្តីពីបច្ចុប្បន្នភាពឧបករណ៍តាមដាន និងវាយតម្លៃប្រចាំឆ្នាំ ដើម្បីបង្កើនប្រសិទ្ធភាពការអនុវត្តប្រព័ន្ធតាមដាន និងវាយតម្លៃជាតិឆ្ពោះទៅសម្រេចបាននូវគោលដៅសូន្យ៣ (គ្មានការចម្លងថ្មី គ្មានការរើសអើង គ្មានការស្លាប់) នាថ្ងៃ ទី៨ -១០ ខែកក្កដា ឆ្នាំ២០១៤។

២-ក្រុមប្រឹក្សាគោលនយោបាយ និងក្រុមប្រឹក្សាបច្ចេកទេស:

-បានចូលរួមទិវាពិភពលោកប្រយុទ្ធនឹងជំងឺអេដស៍ទី១ធ្នូ ដែលបានប្រារព្ធធ្វើនៅថ្ងៃទី២៧ ខែវិច្ឆិកា


កាច់ជ្រុងវិថីលេខ ១៣ និង ១០២ សង្កាត់វត្តភ្នំ ខណ្ឌដូនពេញ
ទូរស័ព្ទ (៨៥៥) ២៣-៧២៤៨០៩/៤២៤២៤៦
ទូរសារ (៨៥៥) ២៣-៤២៦៥៨១/៤២៦០០៥/៧២៤៨០៩

ឆ្នាំ២០១៤ នៅសាលសន្និសិទ្ធចតុមុខ ក្រោមអធិបតីរបស់ **ឯកឧត្តម កែ គឹមយ៉ាន ឧបនាយករដ្ឋមន្ត្រី** ប្រធានអាជ្ញាធរជាតិប្រយុទ្ធប្រឆាំងនិងគ្រឿងញៀន តំណាងដ៏ខ្ពង់ខ្ពស់ **សម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន នាយករដ្ឋមន្ត្រីនៃព្រះរាជាណាចក្រកម្ពុជា។**

-បានចូលរួមសម័យប្រជុំពេញអង្គលើក ទី១ នាថ្ងៃទី១៩ ខែ មិថុនា ឆ្នាំ ២០១៤ និង ប្រជុំពេញអង្គលើកទី២ នាថ្ងៃទី២១ ខែតុលា ព្រមទាំងសន្និបាតបូកសរុបលទ្ធផលការងារឆ្នាំ២០១៤ និង លើកទិសដៅឆ្នាំ ២០១៥ នាថ្ងៃទី២២ ខែតុលា ឆ្នាំ២០១៤ របស់ អ.ជ.ប.ជ.អ. ។

៣-គណៈកម្មាធិការប្រយុទ្ធនឹងជំងឺអេដស៍ក្រសួងប្រៃសណីយ៍ និងទូរគមនាគមន៍ បានធ្វើរបាយការណ៍តាមការកំណត់ផ្ញើជូន អ.ជ.ប.ជ.អ.។

### ខ-សកម្មភាពផ្ទាល់នៅក្នុងក្រសួង

-បានធ្វើបទអន្តរាគមន៍ចូលរួមសន្និបាតប្រចាំ ២០១៣ និង លើកទិសដៅ ឆ្នាំ២០១៤ របស់ក្រសួង ប.ទ នាថ្ងៃទី២៦-២៧ ខែមីនា ឆ្នាំ២០១៤ ។

-បានធ្វើផែនការសកម្មភាពប្រចាំឆ្នាំ២០១៤។

### គ-សកម្មភាពក្រៅក្រសួង

ក្រុមប្រឹក្សាគោលនយោបាយ:

-បានចូលរួមកម្មវិធីប្រកាសដាក់ឲ្យដំណើរការគម្រោង " **រៀនពីការរស់ នៅ-កម្ពុជា** " ( Learning about living-Cambodia) ដោយប្រើប្រាស់លេខទូរស័ព្ទខ្លី៤ខ្ទង់ **១២៩៣** (ផ្តល់ដោយ TRC និងក្រសួងបទ.) ក្នុងការផ្ញើនិងទទួលសារ ដោយមិនគិតថ្លៃ ជាមួយអ្នកជំនាញនៃមណ្ឌលប្រឹក្សាអង្គការ One World ទាក់ទងនឹងសុខភាពបន្តពូជ សុខភាពផ្លូវភេទ ការបង្ការមេរោគអេដស៍ រក្សាការសម្ងាត់ មិនមានការវិនិច្ឆ័យប្រកបដោយវិជ្ជាជីវៈ ដែលបានប្រព្រឹត្តទៅ នៅសណ្ឋាគារ Intercontinental នាថ្ងៃទី២៨ ខែមីនា ឆ្នាំ២០១៤។

-បានផ្តល់ការប្រឹក្សាដល់តំណាងអង្គការ One World នៅកម្ពុជា ស្តីអំពីការស្វែងរកការសហការបន្តបន្ថែមពីបណ្តាប្រតិបត្តិករទូរស័ព្ទចល័តផ្សេងទៀត បន្ទាប់ពីទទួលបានការចូលរួមគាំទ្រពីក្រុមហ៊ុន Cellcard។

-បានទទួលជួបពិភាក្សាតាមការស្នើសុំតាមរយៈ និងដឹកនាំដោយ **ឯ.ឧ. តែង គន្ធី** អគ្គលេខាធិការអាជ្ញាធរជាតិប្រយុទ្ធនឹងជំងឺអេដស៍ ដើម្បីផ្តល់ប្រឹក្សា ពិគ្រោះយោបល់ ដល់តំណាងអង្គការ **សុខភាពគ្រួសារអន្តរជាតិ FHI360** (Family Health International 360) អំពីនីតិវិធីនៃការស្នើសុំលេខកូដទូរស័ព្ទខ្លី៤ខ្ទង់ សម្រាប់ជាប្រយោជន៍ដល់សាធារណជន ជាពិសេសក្រុមគោលដៅបីៈ ក្រុមស្រីស្រស់ ក្រុមបុរសស្រឡាញ់បុរស ក្រុមនារីក្លឹបសេវាកំសាន្តសប្បាយ ក្នុងការ**និយាយ**សុំប្រឹក្សាចង់ដឹងអំពីបញ្ហាអេដស៍ តាមទូរស័ព្ទដោយឥតគិតថ្លៃ នាថ្ងៃទី១២ ខែវិច្ឆិកា ឆ្នាំ២០១៤ នៅការិយាល័យប្រធានគណៈកម្មាធិការប្រយុទ្ធនឹងជំងឺអេដស៍ក្រសួងបទ.។

## II-ទិសដៅការងារសម្រាប់ ឆ្នាំ២០១៥

១-ចូលរួមអន្តរាគមន៍ តាមរយៈប្រតិបត្តិករទូគមនាគន៍កម្ពុជា ស្នើទៅប្រតិបត្តិករទូរស័ព្ទចល័តទាំងអស់ ក្នុងការចូលរួមសរសេរសារ SMS ខ្លីៗបញ្ជូនទៅកាន់ទូរស័ព្ទដៃ ទាក់ទងការអប់រំ អំពីជំងឺអេដស៍ និង អំពីគ្រឿងញៀន តាមសំណើអាជ្ញាធរជាតិប្រយុទ្ធនឹងជំងឺអេដស៍ និង អាជ្ញាធរជាតិប្រយុទ្ធប្រឆាំងគ្រឿងញៀន ក្នុងឱកាសបុណ្យជាតិ ឬព្រឹត្តិការណ៍សំខាន់នានា តាមការស្នើសុំរបស់អាជ្ញាធរជាតិទាំងពីរ ដើម្បីជួយទប់ស្កាត់ការរីករាលដាលជំងឺអេដស៍ ឆ្ពោះទៅសម្រេចគោលដៅ **សូន្យ៣** (គ្មានការចម្លងថ្មី គ្មានការរើសអើង គ្មានការស្លាប់) និងទប់ស្កាត់ការប្រើប្រាស់គ្រឿងញៀន។

២-រៀបចំគោលនយោបាយ ផែនការប្រយុទ្ធនឹងជំងឺអេដស៍របស់ក្រសួងប.ទ. ។

៣-បន្តការសហការដោយផ្ទាល់ ឬដោយប្រយោលជាមួយដៃគូរអភិវឌ្ឍន៍នានា(តាមលទ្ធភាពដែលអាចទាក់ទងនិងធ្វើបាន) និងជាមួយ អ.ជ.ប.ជ.អ. ក្នុងការស្វែងរកការគាំទ្រ ដើម្បីអាចសម្រេចផែនការឆ្នាំ។

៤-ចាប់បន្តចុះសួរសុខទុក្ខ ដើម្បីបានផ្សព្វផ្សាយ អប់រំ ណែនាំអំពីចំណេះដឹងទាក់ទងបញ្ហាអេដស៍ មន្ត្រីមន្ទីរបទ.ខេត្ត និង និយោជិក នៃសាខាប្រៃសណីយ៍កម្ពុជា ទូរគមនាគមន៍កម្ពុជា នៅតាមបណ្តាខេត្តដែល

ពុំទាន់បានធ្វើនៅឡើយនាពេលកន្លងមក។

៥-ផ្ញើសំណើទៅប្រតិបត្តិករទូរសព្ទ័និងក្រុមហ៊ុនផ្តល់សេវាទូរគមនាគមន៍ដទៃទៀត ដែលស្ថិតក្រោម ក្រោមអាណាព្យាបាលរបស់ក្រសួងប.ទ.បង្កើតឲ្យមានតំណាងនិយោជិកជាបណ្តាញសហការជាមួយគណៈកម្មាធិការប្រយុទ្ធនឹងជំងឺអេដស៍ក្រសួងប.ទ. ងាយស្រួលចូលរួមសហការក្នុងសកម្មភាពប្រយុទ្ធនឹងជំងឺអេដស៍ឬផ្សព្វផ្សាយអប់រំបន្តដល់បុគ្គលិក ព្រោះជាសកម្មភាពពហុវិស័យ។

៦-ប្រជុំការងាររបស់គណៈកម្មាធិការប្រយុទ្ធនឹងជំងឺអេដស៍ដើម្បីពិនិត្យលើសកម្មភាពអនុវត្តការងារ និងបន្តសម្រាប់ត្រីមាសក៏ដូចជាឆមាសបន្ទាប់ ឲ្យបានសំរេចតាមផែនការរបស់ខ្លួន។

៧-តាមដានត្រួតពិនិត្យ និងបន្តជួយផ្តល់ប្រឹក្សា ឬអន្តរាគមន៍ ដល់អង្គការដែលទទួលបានលេខទូរស័ព្ទខ្លីពីក្រសួងបទ.សម្រាប់ធ្វើសកម្មភាពពាក់ព័ន្ធនឹងការអប់រំអំពីជំងឺអេដស៍ សុខភាពផ្លូវភេទ សុខភាពបន្តពូជ ដែលជាមធ្យោបាយថ្មីតាមសេវាទូរគមនាគមន៍កំពុងពេញនិយម ដោយសហការជាមួយអាជ្ញាធរជាតិប្រយុទ្ធនឹងជំងឺអេដស៍ ។

៨-សហការជាមួយប្រៃសណីយ៍កម្ពុជា ក្នុងការបោះពុម្ពឈុតតែមប្រៃសណីយ៍ដែលមានរូបភាពទាក់ទងការអប់រំអំពីមេរោគអេដស៍/ជំងឺអេដស៍ តាមការស្នើសុំរបស់អាជ្ញាធរជាតិប្រយុទ្ធនឹងជំងឺអេដស៍ជាអ្នកផ្តល់រូបភាព។

III-**បញ្ហាប្រឈមៈ**

-រាល់សកម្មភាពការងារប្រយុទ្ធនឹងជំងឺអេដស៍ ទាមទារជាចាំបាច់នូវសម្ភារៈនិងថវិកា និង ការចូលរួមគាំទ្រជាអាទិភាព ។

-វិស័យប្រៃសណីយ៍ និងទូរគមនាគមន៍ បច្ចេកវិទ្យាគមនាគមន៍និងព័ត៌មាន ជាវិស័យដែលអាចជួយចូលរួមទប់ស្កាត់មេរោគអេដស៍/ជំងឺអេដស៍ តាមរយៈសារអប់រំជាដើម បានទូលំទូលាយ ប៉ុន្តែការចូលរួមសហការអាស្រ័យលើឆន្ទៈរបស់ប្រតិបត្តិករទូរស័ព្ទចល័ត ដែលនៅមានកម្រិតនៅឡើយ។

-ការស្រាវជ្រាវស្រង់មន្ត្រីរាជការដែលមានផ្ទុកមេរោគអេដស៍/ជំងឺអេដស៍ នៅតែជាបញ្ហាអនុវត្តពុំទាន់បាន ទោះបីមានការយល់ដឹងក៏ដោយ។

IV-**សំណូមពរៈ**

ដើម្បីគណៈកម្មាធិការប្រយុទ្ធនឹងជំងឺអេដស៍ក្រសួងប្រៃសណីយ៍ និងទូរគមនាគមន៍មានលទ្ធភាពអាចធ្វើការសម្របសម្រួលជាមួយប្រៃសណីយ៍កម្ពុជាក្នុងការបោះពុម្ពឈុតតែមប្រៃ ដែលមានគ្រោងក្នុងទិសដៅ ឬ ផែនការឆ្នាំ២០១៥ ដែរនោះ សូមអាជ្ញាធរជាតិប្រយុទ្ធនឹងជំងឺអេដស៍ មេត្តាចាត់ចែងយ៉ាងណា ជួយផ្តល់ឲ្យបានឆាប់តាមលទ្ធភាពដែលអាចធ្វើបាន នូវរូបភាពដែលពាក់ព័ន្ធនឹងការអប់រំអំពីមេរោគអេដស៍/ជំងឺអេដស៍ កុំបីខកខាន។

អាស្រ័យដូចបានជម្រាបជូនខាងលើ សូម **ឯកឧត្តមទេសរដ្ឋមន្ត្រី** មេត្តាជ្រាបជារបាយការណ៍ និងដាក់ចូលក្នុងផែនការឆ្នាំ២០១៥ របស់ក្រសួង ស្ថាប័នជាសមាជិករបស់អ.ជ.ប.ជ.អ. ព្រមទាំងមេត្តាជួយដោះស្រាយសំណូមពរ តាមការគួរ។

សូម **ឯកឧត្តមទេសរដ្ឋមន្ត្រី** មេត្តាទទួលនូវសេចក្តីគោរពដ៏ស្មោះអំពីខ្ញុំ។

រាជធានីភ្នំពេញថ្ងៃទី ០៤ ខែ កុម្ភៈ ឆ្នាំ២០១៥

**រដ្ឋលេខាធិការ**

និង ជាប្រធាន គ.ប.ជ.អ.ប.ទ

**ខាយ ឃុនឆេង**

ចម្លងជូនៈ

-ឯកឧត្តមរដ្ឋមន្ត្រី

" ដើម្បីគោរពជូនជ្រាប "

-ឯកសារ-កាលប្បវត្តិ